## Alien Tort Statute[1] (ATS)

១. ច្បាប់ ATS ត្រូវបានអនុម័តក្នុងឆ្នាំ១៧៨៩ បើកផ្លូវឲ្យតុលាការសហព័ន្ធទទួលពាក្យបណ្តឹងរដ្ឋប្បវេណី ប្តឹងដោយជនជាតិណាមួយក្នុងសហរដ្ឋអាមេរិក ប្រឆាំងនឹងជនបរទេស ដែលបានរំលោភសិទ្ធិមនុស្សនៅទីណាក៏ដោយ។ វាជាយន្តការបណ្តឹងរដ្ឋប្បវេណី មិនមែនបណ្តឹងព្រហ្មទណ្ឌទេ។ ហេតុផលដែលនាំឲ្យកើតច្បាប់នេះឡើង ដោយសារមានទស្សនថា ច្បាប់អន្តរជាតិជាច្បាប់ធម្មជាតិ ដែលចងកាតព្វកិច្ចដល់រដ្ឋាភិបាលទាំងអស់។ ATS ជាយាន្តក្នុងការរកដំណោះស្រាយ និង ដាក់អ្នកប្រព្រឹត្តទង្វើបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ដូចជា អំពើប្រល័យពូជសាសន៍ ឲ្យទទួលខុសត្រូវ។

២. សំណុំរឿងដំបូងគឺ Filartiga (http://www.measboralaws.com/detail/1036) ពាក់ព័ន្ធនឹងការបំពានសិទ្ធិដូចជា សិទ្ធិរួចផុតពីទារុណកម្ម កើតមាននៅក្នុងប្រទេស ប៉ារ៉ាហ្គាយ។ តុលាការផ្តល់សំណង ១០លានដុល្លា ដល់ដើមបណ្តឹង ទោះបីជាលុយជាក់ស្តែងមិនត្រូវបានទទួលក្តី។ ក្រោយមកទៀត សំណុំរឿងមានកាន់តែច្រើន ប្តឹងផ្តល់ប្រឆាំងនឹងបុគ្គល មន្ត្រីរដ្ឋ ឬ សាជីវកម្ម ក្នុងប្រទេស ភូមា បូស្នៀ គោតម៉ាឡា អាហ្សង់ទីណា អែសាវ៉ាឌ័រ នីហ្សេរីយ៉ា ជាដើម។ ទោះបីជាយ៉ាងនេះក្តី សិទ្ធិជាកម្មវត្ថុនៃបណ្តឹងត្រូវបានកម្រិតចំពោះតែសិទ្ធិមួយចំនួន ដែលទទួលឯកភាពជាទូទៅដោយរដ្ឋ (strict standard of international consensus and clear definition)។ នេះដើម្បីកាត់បន្ថយជាយថាហេតុនូវផលប៉ះពាល់ដល់ទំនាក់ទំនងការបរទេស រវាងរដ្ឋនិងរដ្ឋ។ បណ្តឹងទាំងនោះពាក់ព័ន្ធ នឹង ទារុណកម្ម ឧក្រិដ្ឋកម្មសង្គ្រាម ការបាត់ខ្លួន ទាសភាព។ វាមិនទាមទារឲ្យមានចំណងអ្វី ដើម្បីតុលាការអនុវត្តយុត្តាធិការទេ ក៏ប៉ុន្តែ ជាការអនុវត្តជាក់ស្តែង បណ្តឹងកើតមានលើជនល្មើស មានវត្តមានក្នុងទឹកដីអាមេរិក ( អំឡុងពេលធ្វើដំណើរ) ឬ មានពាក់ព័ន្ធនឹង កិច្ចសន្យាជំនួញជាមួយដៃគូ ក្នុងសហរដ្ឋអាមេរិក។

៣. បន្ទាប់ក្រោយមាន សហរដ្ឋអាមេរិកបានអនុម័តច្បាប់ស្រដៀងគ្នានេះចំនួន ២ទៀត៖ ១. The Torture Victim Protection Act in 1992 និង Anti-Terrorism Act in 1990 ដែលជនរងគ្រោះ អាចជាជនបរទេស ឬជនជាតិអាមេរិកនៃអំពើភេរវកម្ម ដើម្បីប្តឹងទារសំណងរដ្ឋប្បវេណី។ បន្ថែមពីលើនេះ មានខលើកលែង (exception) ក្នុងច្បាប់ ស្តីពី អភ័យឯកសិទ្ធិ (Foreign Sovereign Immunities Act: FSIA) បើកផ្លូវឲ្យជនជាតិអាមេរិកប្តឹងប្រឆាំងរដ្ឋាភិបាលមួយចំនួន ដែលគាំទ្រអំ ពើភេរវកម្ម កំណត់ក្នុងបញ្ជី នៃក្រសួងការបរទេស។

ដកស្រង់ចេញពី Beth Stephens, Alien Tort Statute in Dinah L. Shelton, Encyclopedia of GENOCIDE and CRIMES AGAINT HUMANITY, 2005, pp.21-23.

[1] U.S. Code, Vol. 28, Sec. 1350.